ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៨.០៣-០១៧-២៤៤ សរ.ជក

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង

## ស្តីពី ការរៀបចំសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំ២០១៧ និងការទទួលយកសំណើស្រាវជ្រាវ

### សន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំ លើកទី៤ របស់ធនាគារជាតិនៃកម្ពុជា ស្តីពី "តួនាទីរបស់បច្ចេកវិទ្យាក្នុងការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុនៅកម្ពុជា"

ការទទួលបានសេវាហិរញ្ញវត្ថុ ត្រូវបានមជ្ឈដ្ឋាននានាចាត់ទុកថាជាកត្តាគន្លឹះក្នុងការផ្តល់ឱកាសឱ្យប្រជាពលរដ្ឋលើកស្ទួយជីវភាពរស់នៅ និងជំរុញកំណើនសេដ្ឋកិច្ច។ ជាការពិត ការនាំយកសេវាហិរញ្ញវត្ថុទៅបម្រើប្រជាពលរដ្ឋក្រីក្រ ជាពិសេសនៅតាមបណ្តាទីជនបទ គឺជាបញ្ហាប្រឈមក្នុងការពង្រីកបរិយាប័ន្នហិរញ្ញវត្ថុឱ្យកាន់តែមានលក្ខណៈទូលំទូលាយ។ កង្វះខាតនៃហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងបទប្បញ្ញត្តិនិងលក្ខខណ្ឌច្រើនក្នុងការបើកសាខា បានរារាំងដល់ការពង្រីកបណ្តាញប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុនៅតាមតំបន់មួយចំនួន។ ទន្ទឹមនេះ ឧបសគ្គដូចជា ការចំណាយលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រួមទាំងដង់ស៊ីតេប្រជាជនតិច និងចំណូលទាបរបស់ពួកគាត់ គឺជាកត្តាមិនអំណោយផលដល់លទ្ធភាពពង្រីកសាខានៅតាមតំបន់ទាំងនោះ។ ដូចនេះ ការច្នៃប្រឌិតបច្ចេកវិទ្យាថ្មីៗមានតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ ជាពិសេស ក្នុងបរិការណ៍ដែលការពង្រីកសាខានៅទីជនបទនៅតែជាបញ្ហាប្រឈមនៅឡើយ។

គិតត្រឹមឆ្នាំ២០១៦ ប្រជាជនពេញវ័យមានប្រមាណពីរភាគបីនៃចំនួនប្រជាជនសរុប ហើយ ៩៦% មានទូរស័ព្ទចល័តប្រើប្រាស់ និង ៤៨% កំពុងប្រើប្រាស់អ៊ីនធឺណេត។ និន្នាការប្រជាសាស្ត្រសង្គមនេះ រួមទាំងការអភិវឌ្ឍថ្មីៗនៅក្នុងបច្ចេកវិទ្យាហិរញ្ញវត្ថុ និងសេវាធនាគារចល័ត គឺជាកម្លាំងចលករដ៏សំខាន់ ក្នុងការគាំទ្រដល់ការផ្តល់សេវាហិរញ្ញវត្ថុទៅដល់ប្រជាពលរដ្ឋក្រីក្រ។ ការប្រើប្រាស់បច្ចេកវិទ្យាក្នុងវិស័យធនាគារ នឹងរួមចំណែកដល់ការបង្កើនប្រសិទ្ធភាពបន្ថែមទៀតលើការគ្រប់គ្រងហានិភ័យ និងជួយកាត់បន្ថយចំណាយប្រតិបត្តិការ ដែលនឹងធ្វើឱ្យសេវាហិរញ្ញវត្ថុមានតម្លៃទាបជាងមុនសម្រាប់ប្រជាពលរដ្ឋក្រីក្រ។

ដើម្បីលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុនៅកម្ពុជាឱ្យកាន់តែប្រសើរឡើង គឺចាំបាច់ត្រូវ ៖ i/- ស្វែងយល់ពីតួនាទីបច្ចេកវិទ្យានៅក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុនាពេលបច្ចុប្បន្ន ii/- ជំរុញការអភិវឌ្ឍមធ្យោបាយបច្ចេកវិទ្យាថ្មីៗ ដើម្បីបន្តលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ និង iii/- បង្កើតបរិយាកាសអំណោយផលសម្រាប់ការច្នៃប្រឌិតថ្មីៗ ព្រមទាំងកាត់បន្ថយហានិភ័យភ្ជាប់មកជាមួយបច្ចេកវិទ្យា និងធានាឱ្យបាននូវកិច្ចការពារអតិថិជន និងស្ថិរភាពហិរញ្ញវត្ថុ។



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

នៅឆ្នាំ២០១៧នេះ ធនាគារជាតិនៃកម្ពុជា មានសេចក្ដីសោមនស្សរីករាយក្នុងការជម្រាបជូនពីប្រធានបទសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំ លើកទី៨ ស្ដីពី "តួនាទីនៃបច្ចេកវិទ្យាក្នុងការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុនៅកម្ពុជា"។ ធនាគារជាតិនៃកម្ពុជាសូមស្វាគមន៍រាល់ទស្សនៈរបស់អ្នកស្រាវជ្រាវ ព្រមទាំងទទួលនូវធាតុចូលកាន់តែស៊ីជម្រៅលើប្រធានបទខាងលើ។

ដើម្បីរៀបចំសន្និសីទលើប្រធានបទនេះឱ្យបានជោគជ័យ ធនាគារជាតិនៃកម្ពុជាសូមអញ្ជើញអ្នកជំនាញ សេដ្ឋវិទូ និងអ្នកស្រាវជ្រាវដែលមានចំណាប់អារម្មណ៍ ផ្ញើសំណើស្រាវជ្រាវ (Research Proposal) ភ្ជាប់មកជាមួយនឹងប្រវត្តិរូបសង្ខេប (CV) មកកាន់អគ្គនាយកដ្ឋានបច្ចេកទេសនៃធនាគារជាតិនៃកម្ពុជាឱ្យបានមុនថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៧។ អ្នកស្រាវជ្រាវអាចកំណត់ប្រធានបទក្នុងរង្វង់ប្រធានបទគោលខាងលើបាន។ ធនាគារជាតិនៃកម្ពុជានឹងជ្រើសរើសយកសំណើស្រាវជ្រាវទាំងឡាយណាដែលមានគុណវុឌ្ឍិ ដើម្បីធ្វើបទបង្ហាញនៅក្នុងសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំ លើកទី៨ ដែលគ្រោងនឹងប្រព្រឹត្តទៅនៅខែវិច្ឆិកា ឆ្នាំ២០១៧ ខាងមុខនេះ។ ធនាគារជាតិនៃកម្ពុជានឹងផ្ដល់រង្វាន់លើកទឹកចិត្តជូនម្ចាស់អត្ថបទស្រាវជ្រាវដែលទទួលបានជ័យលាភី ព្រមទាំងចុះផ្សាយអត្ថបទស្រាវជ្រាវទាំងនេះនៅលើគេហទំព័រ និងព្រឹត្តិបត្រប្រចាំត្រីមាសរបស់ធនាគារជាតិនៃកម្ពុជា។

**សូមទំនាក់ទំនងមក៖**
**ធនាគារជាតិនៃកម្ពុជា**
**អគ្គនាយកដ្ឋានបច្ចេកទេស**
**នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងសហប្រតិបត្តិការអន្តរជាតិ**
**លេខទូរស័ព្ទ ០២៣ ៩៩០ ១៩៦ / ០១២ ៧៧១ ៩៥០ / ០១៧ ៧០៧ ៧០៩**
**អ៊ីម៉ែល** nbccommunication@nbc.org.kh